


# «ឥរិយាបថនៃជនជាតិចិន នៅកម្ពុជាបច្ចុប្បន្ន»


លោក **ឈុន ផាងេ**

*មន្ត្រីស្រាវជ្រាវផ្នែកទស្សនវិជ្ជានិងសង្គមវិទ្យា*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*នៃរាជបណ្ឌិត្យសភាកម្ពុជា*


២០១៨

# សន្និសីទអន្តរជាតិ
# ស្តីពី
# «តម្លៃវប្បធម៌អាស៊ីប៉ាស៊ីហ្វិកៈ វប្បធម៌, ប្រវត្តិ និងមោទកភាព»

*ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨, ក្រុងសៀមរាប, ខេត្តសៀមរាប*

## ឥរិយាបថនៃជនជាតិចិននៅកម្ពុជាបច្ចុប្បន្ន

THE ATTTITUE OF CHINESE IN CAMBODIA IN THE PRESENT

លោក **ឈុន ផាង៉េ**

*មន្ត្រីស្រាវជ្រាវផ្នែកទស្សនវិជ្ជានិងសង្គមវិទ្យា*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា*

### មូលន័យសង្ខេប

ប្រជាជនខ្មែរ និងប្រជាជនចិនធ្លាប់មានទំនាក់ទំនងផ្នែកវប្បធម៌ជាមួយគ្នាជាយូរណាស់មកហើយ។ ជនជាតិចិនដែលបានមករួមរស់ក្នុងប្រទេសកម្ពុជា ក្នុងអតីតកាលហើយបានជះនិងទទួលឥទ្ធិពលខាងជំនឿប្រពៃណីទំនៀមទម្លាប់វប្បធម៌ទៅវិញទៅមក។ លទ្ធិបិតាធិបតេយ្យរបស់ចិន បានធ្វើសមាហរណកម្មជាមួយលទ្ធិមាតាធិបតេយ្យរបស់ខ្មែរយ៉ាងជ្រៅ ហើយជនជាតិចិន ចេះសម្របខ្លួនរួមរស់ល្អនៅក្នុងសង្គមខ្មែរប្រកបដោយសេចក្ដីសុខដុមរមនា។

នៅពេលបច្ចុប្បន្ននេះដោយសារទំនាក់ទំនងចិនកាន់តែស្អិតល្អួតឡើងថែមទៀត វិនិយោគចិនបាននិងកំពុងសម្រុកចូលមកយ៉ាងគំហុកនៅប្រទេសកម្ពុជា។ ការណ៍នេះបានធ្វើឱ្យលេចធ្លោឡើងនូវបាតុភូតអសកម្មមួយចំនួនគួរឱ្យចាប់អារម្មណ៍ដោយសារតែជនជាតិចិនចំណូលថ្មីខ្លះដែលមានតួនាទីជាអន្តោប្រវេសន៍ បាននិងកំពុងបញ្ចេញសកម្មភាពប្រងេងប្រងាង ដូចជាមានការវាយដំ កាប់ចាក់គ្នា ហាក់ដូចជានៅក្នុងរឿងកុនបុរាណចិន ដោយគ្មានកោតក្រែងម្ចាស់ស្រុកដែលអាចនាំឱ្យមានការថ្នាំងថ្នាក់ និងជះឥទ្ធិពលមិនល្អដល់ទំនាក់ទំនងស្អិតល្អួតរវាងកម្ពុជានិងចិន។ ឥរិយាបថបែបនេះអាចនាំមកនូវការស្អប់ខ្ពើម និងការរើសអើងរវាងជាតិសាសន៍ទាំងពីរ ក្នុងដំណើរអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

អត្ថបទនេះនឹងឆ្លុះបញ្ចាំងពីឥរិយាបថថ្លៃថ្នូររវាងជនជាតិទាំងពីរដែលមានចែងក្នុងវប្បធម៌ចិននិងខ្មែរ ដើម្បីស្វែងរកដំណោះស្រាយសង្គមបច្ចុប្បន្ននៃទំនាក់ទំនងល្អរវាងប្រជាជាតិទាំងពីរឱ្យកាន់តែប្រសើរឡើងថែមទៀត។

## សេចក្តីផ្តើម

បច្ចុប្បន្នទំនាក់ទំនងកម្ពុជាចិនកាន់តែរឹងមាំនិងស្អិតល្មួត។ វិនិយោគទុនចិនស្ទើរគ្រប់វិស័យនៅកម្ពុជាកំពុងមានសន្ទុះខ្លាំងក្លា។ ការណ៍នេះបានលេចនូវបាតុភូតមួយចំនួនគួរឱ្យចាប់អារម្មណ៍ ទាំងវិជ្ជមាននិងអវិជ្ជមាន។ បាតុភូតវិជ្ជមានដែលលេចធ្លោមានដូចជា តម្លៃអចលនវត្ថុ និងការសាងសង់អាគារ ស្ពាន ថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធនានា មានដំណើរការរីកដុះដាលលឿនទូទាំងប្រទេស ជាពិសេសនៅទីតាំងសំខាន់ៗដូចជាទីប្រជុំជន តំបន់ព្រំដែន និងតំបន់ឆ្នេរសមុទ្រ។ ទន្ទឹមនេះបាតុភូតអវិជ្ជមានមួយចំនួនដែលគួរយកចិត្តទុកដាក់និងព្រួយបារម្ភបំផុតគឺ អន្តោប្រវេសន៍ជាតិចិនចំណូលថ្មីមួយចំនួនបាននិងកំពុងបញ្ចេញសកម្មភាពប្រងេងប្រងាង ក្រអឺតក្រអោង វាយដំ កាប់ចាក់គ្នាបំផ្លាញសម្បត្តិឯកជន និងសាធារណៈហាក់មិនញញើតច្បាប់ និងអាជ្ញាធរមានសមត្ថកិច្ចឡើយ។ ទស្សនីយភាពទាំងនេះ គេធ្លាប់តែឃើញមាននៅក្នុងរឿងភាគចិនដែលសំដែងអំពីវិជ្ជាគុនប្រយុទ្ធកាប់ចាក់សងសឹកប៉ុណ្ណោះ។ ឥរិយាបថបែបនេះ អាចនាំមកនូវការស្អប់ខ្ពើម និងការរើសអើងរវាងជាតិសាសន៍ទាំងពីរក្នុងដំណើរអភិវឌ្ឍន៍សង្គមប្រកបដោយនិរន្តរភាព និងអាចជាគុណវិបត្តិដល់ទំនាក់ទំនងជាយុទ្ធសាស្ត្រកម្ពុជាចិនផងដែរ។

តើគួរមានវិធីសាស្ត្របែបណា ដើម្បីទប់ស្កាត់ឥរិយាបថអវិជ្ជមានដែលបង្កឡើងដោយជនជាតិចិននៅកម្ពុជាបច្ចុប្បន្នកុំឱ្យមានគុណវិបត្តិដល់ទំនាក់ទំនងល្អកម្ពុជាចិន?

ពាក្យ«ឥរិយាបថ» នៅទីនេះគឺសំដៅលើអាកប្បកិរិយា ឬជាលំអាននៃសកម្មភាព ការប្រព្រឹត្តទាំងកាយវាចាចិត្តរបស់មនុស្សក្នុងគោលបំណងឬទិសដៅអ្វីមួយ។ យើងដឹងថាមនុស្សគ្រប់ជាតិសាសន៍ តែងតែមានឥរិយាបថក្នុងការរស់នៅមិនដូចគ្នាទាំងស្រុងទេ។ ឥរិយាបថល្អត្រឹមត្រូវ គឺជាអំពើនៃការប្រព្រឹត្តសមរម្យ មិនឆ្គងតាមគន្លងសុជីវធម៌ សីលធម៌ និងគុណធម៌។ ដោយឡែក ពេលនេះសូមផ្តោតទៅលើជ្រុងតូចមួយនៃឥរិយាបថជនជាតិចិនមួយចំនួនដែលមកស្នាក់អាស្រ័យនៅក្នុងប្រទេសកម្ពុជាមកបង្ហាញ ដើម្បីស្វែងរកវិធីសាស្ត្រដោះស្រាយឱ្យបានសមស្របប៉ុណ្ណោះ។

## ១. ប្រវត្តិនៃជនជាតិចិននៅកម្ពុជា

ជនជាតិចិនមានវត្តមាននៅក្នុងប្រទេសកម្ពុជា តាំងពីសតវត្សទី១៣ មកម្ល៉េះ។ គេបានភៀសខ្លួនពីប្រទេសចិន ដោយមូលហេតុគេចចេញពីស្ថានការណ៍លំបាកក្នុងសង្គម ឬបញ្ហាសង្គ្រាមស៊ីវិលនៅប្រទេសចិន ដើម្បីស្វែងរកឱកាសរស់រានមានជីវិត។ គេធ្វើដំណើរផ្សងព្រេងតាមសមុទ្រទាំងប្រថុយប្រថានបំផុត។ មកដល់ស្រុកខ្មែរដំបូងពួកគេមានការក្រែងម្ចាស់ស្រុកមិនហ៊ានក្រអឺតក្រអោងឡើយ។ ខ្មែរហៅចិនភៀសខ្លួនទាំងនោះថា *ចិនឆៅ*។ អន្តោប្រវេសន៍ចិនទាំងនោះ ភាគច្រើនជាបុរសហើយបានរៀបការជាមួយស្ត្រីខ្មែរបង្កើតកូនពូនជាចៅ ដែលខ្មែរនិយមហៅថា *កូនចៅចិន*។ ពួកគេចេះស្វែងយល់ដឹងពីរបៀបរស់នៅក្នុងសង្គមខ្មែរ ចេះសម្របខ្លួនក្នុងសហគមន៍ខ្មែរ មានអាកប្បកិរិយាសមរម្យ ហើយបន្ទាប់មកមានឥទ្ធិពលសេដ្ឋកិច្ចលើសហគមន៍កសិករខ្មែរ។ នេះគឺជាដំណើរការសមាហរណកម្មមួយដែលនាំឱ្យពួកចិនទាំងនោះមានឥរិយាបថចុះសម្រុងទៅនឹងសង្គមធម៌និងវប្បធម៌ខ្មែរ។ ពួកអន្តោប្រវេសន៍ចិននៅក្នុងប្រទេសកម្ពុជានិយាយភាសាខុសគ្នា។ គេឃើញមានចិន៥ត្រកូលធំៗ ដូចជា ចិនទាជីវ (Teochiu) ចិនកន្តាំង (Cantonese) ចិនហៃណាន់ (Hainanese) ចិនខិក (Hakka) និងចិនហុកគាន (Hokkien)។

នៅចុងឆ្នាំ១៩៦០ ចិន ឬកូនចៅចិននៅកម្ពុជាមានចំនួនប្រមាណ ៤២៥ ០០០នាក់។ ចំនួននេះបានធ្លាក់ចុះដោយសារសង្គ្រាម និងដោយសារការកាប់សម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហមប៉ុលពតផង។ នៅក្នុងរបបរសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលនៅក្រោមឥទ្ធិពលវៀតណាម ខ្មែរដែលជាប់ខ្សែស្រឡាយចិន ឬកូនចៅចិនត្រូវបានចុះឈ្មោះក្នុងបញ្ជីលេខ៣៥១។ គោលការណ៍នៃបញ្ជីនេះ គឺជាការកំណត់មុខសញ្ញាដែលត្រូវប្រុងប្រយ័ត្នព្រោះប្រទេសវៀតណាមមានវិវាទជាមួយប្រទេសចិននៅតាមព្រំដែន។ ដើម្បីលាក់អត្តសញ្ញាណរបស់ខ្លួន កូនចៅចិនបានប្តូរឈ្មោះបែបចិនមកឈ្មោះបែបខ្មែរវិញ។ ឆ្នាំ១៩៨៤ ចំនួនខ្មែរកាត់ចិននៅសល់ប្រហែល ៦១០០០នាក់។ ចាប់ពីឆ្នាំ១៩៩៣មក ចំនួនចិនកាត់ខ្មែរកើនឡើងយ៉ាងឆាប់រហ័ស។ ចិនកាត់ខ្មែរបានកើនឡើងដល់ទៅ ៧០០០០នាក់។ ចៅចិនភាគច្រើនមានជីវភាពល្អ សម្បូរអ្នកមានទ្រព្យធន និងមួយចំនួនមានមុខដំណែងខ្ពង់ខ្ពស់ក្នុងជួររដ្ឋាភិបាល[1]។

ពលរដ្ឋខ្មែរដែលមានដើមកំណើតចិន មានពីរប្រភេទគឺ៖ ទី១. *ចិនឆៅ* ដែលបានធ្វើចំណាកស្រុកពីប្រទេសចិនមករស់នៅលើទឹកដីកម្ពុជាតាំងពីយូរយាណាស់មកហើយ។ ទី២. *កូនចៅចិន* គឺពលរដ្ឋជីដូនជីតាឬម្តាយឪពុកជា *ខ្មែរ* ឬ *ចិន*។ ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ជនជាតិចិនដែលចូលមកស្រុកខ្មែរខ្លះមកពីសិង្ហបុរី តៃវ៉ាន់ ហុងកុង និងចិនដីគោក។ ពួកគេមានមុខរបរខុសៗគ្នា ដូចជាមន្ត្រីការទូត ពាណិជ្ជករ វិនិយោគគិន គ្រូបង្រៀនភាសាចិន អ្នកផ្សាយសាសនា វិស្វករ កម្មករជំនាញ។ល។

បច្ចុប្បន្ន ចំនួនពលរដ្ឋខ្មែរដែលមានដើមកំណើតចិន ចិនកាត់ខ្មែរ និងអន្តោប្រវេសន៍ចិនដទៃទៀត កំពុងកើនឡើងនៅកម្ពុជាជាបន្តបន្ទាប់ដោយសារតែកម្ពុជាប្រកាន់យករបបទីផ្សារសេរី និងរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នមានទំនាក់ទំនងល្អជាមួយរដ្ឋាភិបាលចិន។ តាមការប៉ាន់ស្មាន ត្រឹមឆ្នាំ២០១៣ ពលរដ្ឋខ្មែរដែលមានដើមកំណើតចិន និង ចិនកាត់ខ្មែរ មានប្រមាណ១៥២០៥៥នាក់ ស្មើ១%នៃប្រជាជនកម្ពុជាសរុប។ ភាគច្រើននៃពួកគេ កំពុងរស់នៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ ខេត្តបាត់ដំបង ខេត្តកំពត ខេត្តកំពង់ចាម និងខេត្តមួយចំនួនទៀត។

ទោះបីជាពលរដ្ឋខ្មែរដើមកំណើតចិន ឬ ចិនកាត់ខ្មែរ មានចំនួនមិនច្រើនក៏ដោយ ក៏ពួកគេបានចូលរួមយ៉ាងសកម្មក្នុងវិស័យផ្សេងៗក្នុងសង្គមខ្មែរ។ ជាទូទៅ ពួកគេមិនត្រូវបានរើសអើងឬមើលងាយដោយពលរដ្ឋខ្មែរម្ចាស់ស្រុកឡើយ។ ពួកគេ បានដើរតួនាទីនាំមុខគេនៅក្នុងវិស័យអាជីវកម្មនៅកម្ពុជា ក៏ដូចជានៅក្នុងឆាកនយោបាយរបស់ប្រទេសកម្ពុជាផងដែរ។ ភាគច្រើននៃពួកគេ មានឥទ្ធិពលពិសេសនៅក្នុងវិស័យធនាគាររបស់កម្ពុជា ដែលជាសហគ្រាសផ្តល់ប្រាក់កម្ចី សហគ្រាសប្តូរប្រាក់ ស្ថាប័នហិរញ្ញវត្ថុខ្នាតតូច និងសហគ្រាសពាក់ព័ន្ធដទៃទៀត។

## ២. ស្ថានភាពជីវិតជនជាតិចិនក្នុងសង្គមខ្មែរ

ជនជាតិចិន បានចូលមករស់នៅក្នុងសង្គមខ្មែរយ៉ាងសុខសាន្ត ដោយសមារណកម្មក្លាយជាពលរដ្ឋមានសញ្ជាតិខ្មែរយ៉ាងងាយបំផុត។ *ចិនឆៅ* ឬ *កូនចៅចិន* មិនគ្រាន់តែអាចរក្សាប្រពៃណី ទំនៀមទម្លាប់របស់ខ្លួនបានប៉ុណ្ណោះទេ ពួកគេថែមទាំងបានជះឥទ្ធិពលប្រពៃណីរបស់ខ្លួនទៅលើវប្បធម៌ខ្មែរ និងជះឥទ្ធិពលពាណិជ្ជកម្ម សេដ្ឋកិច្ច និងវិស័យផ្សេងៗលើសង្គមខ្មែរផងដែរ។ ជនជាតិចិនបានរក្សាជំនឿ ប្រពៃណី ទំនៀមទម្លាប់របស់ខ្លួន ដូចជា

[1] https://thmeythmey.com/?page=detail&id=36148

ប្រពៃណីបុណ្យចូលឆ្នាំចិន បុណ្យសែនលោកខែ បុណ្យសែនក្បាលទឹក និងបុណ្យឆេងម៉េងជាដើម។ គេមានមុខរបរខុសៗគ្នា ដូចជា អ្នកការទូត ពាណិជ្ជករ វិនិយោគិន វិស្វករ កម្មករជំនាញ ពលករ គ្រូបង្រៀនភាសាចិន អ្នកផ្សាយសាសនា។ល។ ការមានលុយកាក់ច្រើន ការមានទីលំនៅក្នុងរាជធានី ទីក្រុង និងទីប្រជុំជន នាំឱ្យចិនកាត់ខ្មែរ មានឱកាសរៀនសូត្របានខ្ពង់ខ្ពស់ មានឱកាសធ្វើដំណើរបានច្រើនកន្លែង ដែលជាកត្តានាំឱ្យពួកគេមានចំណេះដឹងខ្ពស់ និង មានការយល់ដឹងជ្រៅជ្រះ។ ដោយសារកត្តាទាំងអស់នេះ រួមផ្សំជាមួយឱកាសផ្សេងៗ ដូចជាសំណូកសូកប៉ាន់ អំពើពុករលួយជាដើម បាននាំឱ្យចិនកាត់ខ្មែរទទួលបានតួនាទីសំខាន់ៗក្នុងរដ្ឋាភិបាល និងក្នុងការងាររាជការទូទៅ ជាពិសេសការងារមួយចំនួនដែលគេនិយមហៅថាការងារល្អ ឬការងារកន្លែងខ្លាញ់ ដូចជាការងារគយ ការងារពន្ធដារ ការងារហិរញ្ញវត្ថុ ដែលជាប្រភេទការងារអាចរកកម្រៃ ឬ ចំណូលក្រៅច្បាប់បានច្រើន។ ពួកគេបានចូលរួមក្នុងវិស័យផ្សេងៗភាគច្រើនក្នុងសង្គមខ្មែរ ហើយពួកគេទទួលបានការចូលចិត្ត និងការឱ្យតម្លៃពីសង្គមខ្មែរ។ ហេតុនេះហើយទើបដូនតាខ្មែរបានលើកពាក្យស្លោកថា «កុំឈ្លោះនឹងស្រី កុំក្ដីនឹងចិន»។ ពាក្យស្លោកនេះអាចបញ្ជាក់ថា សង្គមខ្មែរគោរពលទ្ធិមាតាធិបតេយ្យ គឺខ្មែរលើកស្ទួយនិងឱ្យតម្លៃស្ត្រីខ្ពស់បំផុត ការឈ្លោះនឹងស្រីនាំឱ្យអាប់ឱនកិត្តិយស ហើយត្រូវចៀសវាងបង្កក្ដីក្ដាំនឹងចិន ព្រោះចិនប្រើឥទ្ធិពលទឹកលុយពូកែសូកប៉ាន់មន្ត្រីរាជការ។ ចៅក្រមអាចកាត់ក្ដីឱ្យ*មនុស្សស្រី* និង *ចិន*ឈ្នះក្ដីជានិច្ច។

## ៣. មុខរបរជំនាញនៃជនជាតិចិននៅកម្ពុជា

ខ្មែរបុរាណមិនសូវពូកែខាងពាណិជ្ជកម្មដូចជនជាតិចិនឡើយ។ អ្នកលក់ដូរភាគច្រើនជាជនចិន រីឯជនជាតិខ្មែរវិញចូលចិត្តប្រកបរបរកសិកម្ម និង ធ្វើការងាររាជការ។ ខ្មែរខ្លះដែលប្រកបរបរលក់ដូរ គេហៅគាត់ថាចិន ប៉ុន្តែខ្មែរដែលប្រកបមុខរបរនេះមានចំនួនតិចតួចបំផុត។ ជនជាតិចិនស្ទើរតែទាំងអស់ជាអ្នកជំនួញ ឬពាណិជ្ជករ បានកាន់កាប់សេដ្ឋកិច្ចក្នុងទីក្រុងនិងខេត្តសំខាន់ៗរហូតដល់ ៩០% ខណៈដែលជនជាតិខ្មែរសុទ្ធចូលចិត្តប្រកបរបរកសិកម្មស្រែចម្ការ។ ជនជាតិចិនខ្លះប្រកបរបរជាអ្នកលក់គ្រឿងទេស ជាអ្នកចងការប្រាក់ដែលយកការប្រាក់ខ្ពស់តាមទីប្រជុំជន តាមជនបទទូទាំងប្រទេស ខ្លះទៀតបើកសិប្បកម្មកែច្នៃផលិតផលកសិកម្ម ដូចជាកិនអង្ករ ធ្វើម្រេចស្ករត្នោត ផ្លែឈើ ផលិតទឹកត្រី ទឹកស៊ីអ៊ីវ សៀង សាច់ក្រក និងនំចំណីជាដើម ហើយចិនផ្សេងទៀតធ្វើចម្ការ ដូចជានៅខេត្តកំពត និងកោះកុង ដែលគេនិយមហៅថា «ចិនខ្មៅ» ពួកគេប្រកបរបរកសិកម្មដូចដាំម្រេច ធូរេន សារម៉ាវជាដើម។ ពួកគេកាន់កាប់សេដ្ឋកិច្ចស្ទើរតែទាំងស្រុង ហើយបានលក់ទំនិញជឿឱ្យខ្មែរក្រីក្រនៅតាមជនបទ យកការប្រាក់ពី ១០% ទៅ ២០% លើថ្លៃដើមក្នុងមួយខែៗ។ ពីមួយឆ្នាំទៅមួយឆ្នាំប្រជាជនខ្មែរសុទ្ធនៅជនបទប្រហែល ៧៥% បានជំពាក់បំណុលចិន ហើយត្រូវចិន រឹបអូសយកទ្រព្យសម្បត្តិ ដូចជាផ្ទះដីស្រែ គោ ក្របី ជាដើម។ ប្រជាជនខ្មែរនៅតាមជនបទមិនសូវមានចំណេះដឹងជ្រៅជ្រះ ប្រើកម្លាំងបាយសុទ្ធសាធ កាប់គាស់ធរណីប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត ហើយភាគច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា ជឿលើបុណ្យបាប និងមានភាពស្មោះត្រង់។ ខ្មែរដែលមានជីវភាពខ្សត់ខ្សោយតែងតែធ្លាក់ខ្លួនជំពាក់បំណុលចិនកាន់តែច្រើនឡើងៗ ហើយទីបំផុតត្រូវចិនរឹបអូសយកដីធ្លី ស្រែចម្ការ ផ្ទះសម្បែងជាបន្តបន្ទាប់។ ខ្មែរបានត្រឹមតែកាប់ឆ្ការរានដីព្រៃប៉ុណ្ណោះ ទីបំផុតជនជាតិចិនបានទិញយកកន្លែងល្អៗអស់ ឯខ្មែរក៏បន្តទៅកាប់ឆ្ការរានព្រៃថ្មីទៀតជាបន្តបន្ទាប់គឺ «ចិនដេញខ្មែរ ខ្មែរដេញខ្មោច»។ ចិនបានចូលរួមយ៉ាងសកម្មក្នុងវិស័យសេដ្ឋកិច្ចខ្មែរ ខ្លះជាម្ចាស់ភាគហ៊ុន ម្ចាស់រោងចក្រ ម្ចាស់សហគ្រាស ម្ចាស់អា-

ជីវកម្មធំៗ និងជាម្ចាស់ធនាគារដែលជាសហគ្រាសផ្តល់ប្រាក់កម្ចី  សហគ្រាសប្តូរប្រាក់ ស្ថាប័នហិរញ្ញវត្ថុខ្នាតតូច និងសហគ្រាសពាក់ព័ន្ធដទៃទៀត។  ជនជាតិចិនបានដើរតួនាទីនាំមុខស្ទើរគ្រប់វិស័យសំខាន់ៗនៅកម្ពុជា ដូចជាវិស័យពាណិជ្ជកម្ម វិស័យនយោបាយជាដើម។ សហគមន៍ជនជាតិភាគតិចចិនរស់នៅយ៉ាងធូធារនិងយ៉ាងសុខសាន្តក្នុងសង្គមខ្មែរ។

## ៤. ទំនាក់ទំនងវប្បធម៌ចិន និងវប្បធម៌ខ្មែរ



ប្រជាជនខ្មែរ និង ប្រជាជនចិនធ្លាប់មានទំនាក់ទំនងផ្នែកវប្បធម៌ជាមួយគ្នាជាយូរណាស់មកហើយ។ ជនជាតិចិនដែលបានមករួមរស់ក្នុងប្រទេសកម្ពុជា ក្នុងអតីតកាលហើយបានជះ និងទទួលឥទ្ធិពលខាងជំនឿ ប្រពៃណី ទំនៀមទម្លាប់  វប្បធម៌ទៅវិញទៅមក។

ដូចជាករណីចម្លាក់អំពីសិល្បៈសៀកចិន នៅលើប្រាសាទបាយ័នបញ្ជាក់ថានៅក្នុងពិធីបុណ្យទានធំៗ គេឃើញមានការសម្តែងនូវទស្សនីយភាពមួយចំនួនដូចជា ល្បែងឈុតឈរតម្រៀបជាន់លើគ្នា ឈុតជិះដំរីវាយកូនឃ្លី ការបង្វិលខ្លួនលើចុងបង្គោលឈើ ឈុតដើរស្ទូរលើព្រ័ត្រ ឈុតលេបកាំបិតវែងនិងខ្លី និងឈុតលើកទម្ងន់ជាដើម ដែលបុព្វការីជនខ្មែរបាននិយមបដិបត្តិនាចុងសតវត្សរ៍ទី១២។

ប្រសិនបើយើងទស្សនាឈុតសៀកចិនបច្ចុប្បន្នខ្លះ យើងមានអារម្មណ៍ថា មានលក្ខណៈដូចគ្នា នឹងឈុតឆ្លាក់លើថ្មប្រាសាទ ដោយកាយវិការដែលជាមូលហេតុធ្វើឱ្យយើងឃើញមានសម្ព័ន្ធភាពផ្នែកទស្សនីយភាពរវាងជនជាតិចិននិងខ្មែរ។ តាមចម្លាក់គេឃើញថា កាយវិការ សម្លៀកបំពាក់ និងបរិបទវប្បធម៌សង្គមខ្មែរ ដែលខ្មែរជាអ្នកសំដែងសម្រាប់បង្ហាញមហាជនក្នុងព្រះរាជធានី មិនមែនចិនបែបចិនទេ។ មានន័យថាសិល្បករខ្មែរមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសឈុត និងទីតាំងសម្រាប់សំដែងដោយមិនបានស្លៀកពាក់ ឬប្រគុំទំនុកបទភ្លេងតាមបែបចិនឡើយ។

## ៥. អត្តសញ្ញាណជនជាតិចិន

ខ្មែរសរសើរជនជាតិចិនថាជាមនុស្សស្អាត។ ពេលខ្មែរណាម្នាក់មានកូនសម្បុរសជ្រះ គេនិយាយថា សស្អាតដូចកូនចិន។ អញ្ចឹងហើយទើបស្ត្រីខ្មែរខ្លះខិតខំប្រើម្សៅលាបលន សំអិតសំអាងធ្វើឱ្យស្បែកសដូចចិន។ បុរសខ្មែរដែលបានស្ត្រីកូនចៅចិនរៀបការជាមួយ គឺជាបុរសដែលមានសំណាងខ្ពស់ ព្រោះបានទាំងសាច់ឈាមព៌ណសម្បុរសស្អាត បានទាំងជីវភាពប្រសើរ ហើយបានកូនមកឆ្លាតពូកែរកស៊ី។ ចំណែកបុរសកូនចៅចិនដែលបានរៀបការជាមួយស្ត្រីខ្មែរភាគច្រើនមិនសូវលើកកម្ពើងប្រពន្ធទេព្រោះឥទ្ធិពលនៃគំនិតបិតាធិបតេយ្យដែលលើកតម្កើងមនុស្ស

ប្រុសជាងមនុស្សស្រី។ ស្ត្រីខ្មែរដែលរៀបការជាមួយកូនចៅចិន ភាគច្រើនត្រូវទៅរស់នៅផ្ទះខាងប្តី ហើយជាធម្មតាស្ទើរតែក្លាយជាអ្នកបំម្រើរបស់បងប្អូនឪពុកម្តាយខាងប្តីទាំងស្រុង។ មនុស្សប្រុសកូនចៅចិនមានតម្លៃខ្លាំងប្រៀបដូចព្រះរាជបុត្រា។ ប្រសិនបើស្ត្រីជាប្រពន្ធអាចបង្កើតបានកូនប្រុសច្បងនោះគឺជាគុណតម្លៃមួយយ៉ាងពិសេសបំផុត។ ពួកចិនចង់បានកូនប្រុសដើម្បីដាក់ឈ្មោះនាមត្រកូល ស្នងពូជពង្សវង្សត្រកូលតរៀងទៅ។ ទាំងនេះគឺជាអត្ត-សញ្ញាណពិសេសមួយរបស់ជនជាតិចិន។ អត្តសញ្ញាណចិនដទៃទៀតស្ថិតនៅលើកាយវិការ ភាសាពាក្យសំដី និងជំនឿជាដើម។ ក្នុងជីវភាពប្រចាំថ្ងៃនៅតាមទីប្រជុំជនឬជនបទ កូនចៅចិន ប្រើការហៅ បងប្រុស បងស្រី ពូ មីងជាភាសាចិន ដូចជាពាក្យ ហ៊ា ចែ ទ្រា អ៊ី គូ ទា ប៉ិ។ល។ ចិននិយមទទួលទានអាហារដោយប្រើចង្កឹះ។ អាហារដូចជានំប៉ាវ ឆាខ្វៃ គុយទាវ មី ជាដើមមានលក់ជាប្រចាំ។ នៅរដូវសែនព្រេនឆេងម៉េង ចូលឆ្នាំចិន គេនាំគ្នាពូនផ្នូរជូនតា ដុតក្រដាសសែន ដុតផាវ និងហែម៉ុងសាយ។ គេជូនអាំងប៉ាវ តមឈ្លោះជេរបញ្ចោរគ្នា មិននិយាយពាក្យអសុរស ខិតខំធ្វើល្អ ប្រព្រឹត្តអំពើត្រឹមត្រូវ និងក្រើនរំលឹកដាស់តឿនគ្នាឱ្យខិតខំធ្វើការរកស៊ីកុំឱ្យខ្ជិលច្រអូស។ ចិននិយមពណ៌ក្រហម ដែលជានិមិត្តរូបនាំមកមហាលាភសំណាងដ៏ធំចូលមកក្នុងគ្រួសារ ទន្ទឹមនេះគេលើកតម្លៃដើមផ្កាអង្គារសីលដែលផ្កាវាមានពណ៌លឿងផងដែរ។ អត្តសញ្ញាណចិននេះ ក៏ឃើញមានការបង្ហាញនៅគ្រប់ប្រទេសដែលមានប្រជាជនចិនរស់នៅ ដូចជា ចិនដីគោក ហុងកុង ម៉ាកាវ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ហ្វីលីពីន សិង្ហបុរី តៃវ៉ាន់ វៀតណាម ជប៉ុន កូរ៉េ ម៉ុងហ្គោលី និងទីប្រជុំជនចិនផ្សេងៗទៀត។



នៅទីក្រុងភ្នំពេញ ថ្ងៃសែនចិនកូនកាត់ចិន បាននាំគ្នាសែនយ៉ាងកុះករ ស្ទើតែគ្រប់គ្នា។

https://tresdichak.wordpress.com/2013/02/09/សែនចិន/

យោងតាមការសង្កេតទៅលើវប្បធម៌និងសង្គមធម៌ចិន យើងអាចកត់សម្គាល់ជាទូទៅថា ចិនជាជនជាតិមួយមានអត្តចរិត ដឹងគុណ ចេះជួយទុក្ខធុរៈគ្នា ចេះឃឹតយោងលើកស្ទួយពូជពង្សវង្សត្រកូលឱ្យថ្កុំថ្កើង មានចិត្តអង់អាចក្លាហានមោះមុតហ៊ានពុះពារគ្រប់ឧបសគ្គ ធ្វើពលិកម្មប្រយុទ្ធប្រឆាំងខ្លាំងសត្រូវ។ តាមរយៈអក្សរសិល្ប៍ ជាទូទៅបានអប់រំមនុស្សឱ្យចេះតស៊ូរើបម្រះចេញពីអំពើអយុត្តិធម៌ ស្វែងរកការពិត និងតាមសងសឹកជូនអ្នកមានឧបការគុណ។ល។

ជនជាតិចិនប្រើឥទ្ធិពលទឹកលុយដើម្បី ផ្សព្វផ្សាយភាសាចិន ខ្សែភាពយន្តចិន និងជំនឿប្រពៃណីចិន រីកដុះដាលពេញផ្ទៃប្រទេស។ ស្ថានីយ៍ទូរទស្សន៍ខ្មែរស្ទើរតែទាំងអស់តែងចាក់បញ្ចាំងរឿងរបស់ចិន ដូចជារឿងភាគបុរាណចិន និងរឿងបែបទំនើប ដោយមានជាជនខ្មែរជាច្រើនចូលចិត្តតាមដានទស្សនា។ ខ្មែរភាគច្រើនព្រមទទួលជឿជាក់ និងយកតម្រាប់តាមរបៀបសែនព្រេនតាមលំនាំចិន។ ខ្មែរជឿថា ចិនរកស៊ីមានបានសម្បូរដោយសារចិនចេះគោរពដឹងគុណនិងសែនជូនតាខ្លួន ឬសែនអ្នកតាចិនជាដើម។ ខ្មែរចូលរួមយ៉ាងសកម្មក្នុងពិធីបុណ្យចូលឆ្នាំចិន បុណ្យសែនលោកខែ បុណ្យសែនក្បាលទឹក បុណ្យឆេងម៉េង។ល។ ស្ថាប័នខ្មែរខ្លះឈប់សម្រាកពេលចូលឆ្នាំចិន។ អត្តសញ្ញាណជំនឿចិន មានស្ទើរគ្រប់ផ្ទះខ្មែរទាំងអស់។

## ៦. ឥរិយាបថទេសចរជនជាតិចិននៅកម្ពុជា

យោងតាមច្បាប់ស្តីពីអន្តោប្រវេសន៍កម្ពុជា បញ្ជាក់ថា ទេសចរជនជាតិចិន មិនចាត់ទុកជាអន្តោប្រវេសន៍ចិនទេ[2]។ ទេសចរជនជាតិចិន មានអាកប្បកិរិយាធ្វើឱ្យគេអាចសម្គាល់អត្តសញ្ញាណចិនបានដោយសារអត្តចរិតដោយឡែក គឺជនជាតិចិនមានដំណើរ កាយវិការរវៀសរវៃ ស្វាហាប់ ប្រងាងពេញផ្លូវ និយាយសំឡេងកកោកកងរំពងមិនសូវស្ងាត់បង្កនូវបរិយាកាសអ៊ូអែ។ ទេសចរជនជាតិចិនដែលបានមកទស្សនាកម្ពុជានៅឆ្នាំ២០១៧ ឈរក្នុងលំដាប់លេខ១ គឺក្នុងចំណោមទេសចរបរទេស ៥,៦លាននាក់ មានទេសចរជនជាតិចិនចំនួន ១.២១០.៧៨២នាក់ នាំប្រាក់ចំណូលប្រមាណ ៣៦៣៨លានដុល្លារអាម៉េរិកចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិ រួមចំណែក១៣%នៃផលិតផលក្នុងស្រុកសរុប(GDP) ។

ក្នុងរយៈពេល៤ខែដើមឆ្នាំ២០១៨ កម្ពុជាទទួលបានភ្ញៀវទេសចរចិន(ទេសចរជនជាតិចិន) ចំនួន ៦៤៧.៣៥២នាក់ កើនឡើង ៧៩,៤% បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ ដែលមានចំនួន ៣៦០.៧៨៣នាក់។ នេះជាជំហានឈានមួយឆ្ពោះទៅទទួលបានចំនួនកើនឡើងដល់យ៉ាងតិច ២លាននាក់នៅឆ្នាំ ២០២០។ តាមការព្យាករណ៍ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិប្រមាណ ៦,២លាននាក់ នៅឆ្នាំ២០១៨ និងនឹងកើនដល់ ៧លាននាក់ នៅឆ្នាំ២០២០ ដែលនាំមកនូវចំណូលប្រមាណ ៥.០០០លានដុល្លារ បង្កើតនូវឱកាសការងារដល់ពលរដ្ឋខ្មែរចំនួន១លាននាក់ ហើយនៅឆ្នាំ២០៣០ នឹងទទួលបានភ្ញៀវទេសចរអន្តរជាតិ ១៥លាននាក់ ដោយនាំមកនូវចំណូលសរុប ១០.០០០លានដុល្លារ ដោយបង្កើតនូវឱកាសការងារដល់ពលរដ្ឋខ្មែរចំនួន២លាននាក់។[3]

វិស័យទេសចរណ៍អាចជួយធានានិរន្តរភាពការងារដល់ពលរដ្ឋរាប់លាននាក់ នាំមកនូវថវិការាប់លានដុល្លាក្នុងសកម្មភាពសេដ្ឋកិច្ចជាតិជារៀងរាល់ឆ្នាំ។ ដើម្បីសម្រេចគោលបំណង កាត់បន្ថយភាពក្រីក្រ និង បង្កើនកំណើនសេដ្ឋកិច្ច ដោយរក្សាបានបរិស្ថានល្អនិងការពារបាននូវតម្លៃវប្បធម៌ជាតិ យើងគួរប្រើឥទ្ធិពលនៃទំនាក់ទំនងកម្ពុជាចិន ដើម្បីបង្កើនការវិនិយោគលើវិស័យនេះ និងទាក់ទាញភ្ញៀវទេសចរចិនឱ្យអស់សក្តានុពលភាព ព្រោះប្រជាជនចិនមានចំនួនជិតដល់១៣៧៤០លាននាក់[4] គឺច្រើនជាងគេលើពិភពលោក។

---

[2] យោងតាមច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៩៤នៃព្រះរាជាណាចក្រកម្ពុជា គេអាចកំណត់អត្តសញ្ញាណជនជាតិចិនដូចតទៅ៖ ជនអន្តោប្រវេសន៍ចិន គឺពលរដ្ឋចិនដែលមកដល់ព្រះរាជាណាចក្រកម្ពុជាដើម្បីស្នាក់នៅរយៈពេលយូរ ដើម្បីប្រកបវិជ្ជាជីវៈ ឬធ្វើសកម្មភាពផ្សេងៗដែលទាក់ទងនឹងឧស្សាហកម្ម ពាណិជ្ជកម្ម សេវា ឬកសិកម្ម។ ចំណែកចិនមិនមែនអន្តោប្រវេសន៍ គឺជនជាតិចិនដែលចូលមកព្រះរាជាណាចក្រកម្ពុជាតាមការស្នើសុំ ឬតាមកិច្ចព្រមព្រៀង ឬអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា មានដូចជា៖ ភ្នាក់ងារទូត បេសកជន អ្នកជំនាញការ បុគ្គលិក ទាហាន មន្ត្រី អ្នករដ្ឋការ និយោជិតនិងភ្នាក់ងារ និស្សិតនិងគ្រួសារ អ្នកតំណាងពាណិជ្ជកម្ម ធនាគារ កងនាវិកនិងយានិក ដែលមកសំចតយកស្បៀងនៅតាមកំពង់ផែសមុទ្រ និងតាមព្រលានយន្តហោះ និងអ្នកដែលមកធ្វើការនេសាទនៅតាមឆ្នេរសមុទ្រ អ្នកទេសចរ និងអ្នកធ្វើដំណើរឆ្លងកាត់។

[3] ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ថ្លែងក្នុងពិធីលាងសាយភោជន៍ ក្នុងឱកាសបើកពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦០នៃទំនាក់ទំនងការទូតកម្ពុជា-ចិន នៅក្នុងក្រុងសៀមរាប នារាត្រីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។

[4] http://km.rfi.fr/ ប្រជាសាស្ត្រ-ចិន-កំណើនប្រជាជន-គ្រួសារមួយកូនម្នាក់-ផែនការ៥ឆ្នាំ-05-03-2016




៤ខែដើម ឆ្នាំ២០១៨ កម្ពុជាទទួលទេសចរចិន ចំនួន ៦៤៧.៣៥២នាក់ គឺកើន ៧៩,៤% បើគិតរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ មានចំនួន ៣៦០.៧៨៣នាក់ ។ កំនើននេះអាចទស្សន៍ទាយថា នៅឆ្នាំ២០២០ នឹងមានទេសចរចិន ២លាននា

## ៧. ឥរិយាបថបរទេសជនជាតិចិននៅកម្ពុជានាសតវត្សទី២១

ជនបរទេសជនជាតិចិននៅកម្ពុជានាសតវត្សទី២១ មានលក្ខណៈខុសប្លែកពីជនភៀសខ្លួនជនជាតិចិនសម័យមុន។ សម័យមុនជនជាតិចិនមកកម្ពុជាក្នុងលក្ខណៈជាជនភៀសខ្លួនគេចចេញពីសង្គ្រាមស៊ីវិល ឬគ្រាន់តែស្វែងរកការរស់រានមានជីវិតពីការធ្វើទុកបុកម្នេញពីកំណែទម្រង់គោលនយោបាយប្រទេសចិនប៉ុណ្ណោះ ចំណែកជនបរទេសជនជាតិចិន ឬអន្តោប្រវេសន៍ចិនសតវត្សទី២១ តើអាចជាគោលបំណងដើម្បីសម្រេចមហិច្ឆតានៃគោលនយោបាយសេដ្ឋកិច្ច ផ្លូវមួយខ្សែក្រវ៉ាត់មួយឬយ៉ាងណា? តើគេអាចនិយាយបានថា គោលបំណងនៃអន្តោប្រវេសន៍ចិនពេលនេះគឺផ្តោតតែទៅលើហេតុផលសេដ្ឋកិច្ចជាចម្បងឬយ៉ាងណា? តើអន្តោប្រវេសន៍ចិននៅកម្ពុជា ជាការអនុវត្តនូវមហិច្ឆតារបស់រដ្ឋាភិបាលចិន ដែលចង់ពង្រីកឥទ្ធិពលនយោបាយសេដ្ឋកិច្ច ដើម្បីដណ្តើមយកកិត្យានុភាពភូមិសាស្ត្រនយោបាយ ឬពង្រីកតួនាទីជាមហាអំណាចលើពិភពលោកឬយ៉ាងណា?

ចុងឆ្នាំ២០១៨នេះ ជនជាតិចិន នឹងមកកម្ពុជាប្រមាណជាង៥ម៉ឺននាក់ដើម្បីប្រកបអាជីវកម្មផ្សេងៗខណៈនៅកម្ពុជាមានថៅកែចិនកំពុងសាងសង់អាគារធំៗជាច្រើនផងដែរ[5]។ ការកើនឡើងយ៉ាងគំហុកនៃជនជាតិចិននៅកម្ពុជា ជាពិសេសនៅខេត្តព្រះសីហនុក្នុងរយៈពេលចុងក្រោយនេះ អាចនឹងបង្កទៅជាវិបត្តិធ្ងន់ធ្ងរសម្រាប់ប្រទេសកម្ពុជាទៅថ្ងៃមុខប្រសិនបើមិនមានវិធានការគ្រប់គ្រងច្បាស់លាស់។ ការទទួលយកកម្មករចិនដ៏ច្រើនសន្ធឹកសន្ធាប់គឺជារឿងមួយដែលធ្វើឱ្យខាតប្រយោជន៍ដល់កម្លាំងពលកម្មកម្ពុជាដោយសារតែវាមិនបានផ្តល់ឱកាសការងារដល់ពលរដ្ឋខ្មែរ ហើយពលរដ្ឋខ្មែរនៅតែបន្តធ្វើចំណាកស្រុកដោយប្រឈមគ្រោះថ្នាក់ទៅក្រៅប្រទេស។

ការកើនឡើងយ៉ាងឆាប់រហ័សនៃអន្តោប្រវេសន៍ចិន បានបង្កឱ្យមានបទល្មើសគ្រឿងញៀន វាយកាប់ចាក់សងសឹក សម្លាប់គ្នា និងបង្កបទល្មើសលួច ឆក់ប្លន់ ចាប់ជំរិតជាបន្តបន្ទាប់។ ការណ៍នេះបានគម្រាមកំហែងដល់សន្តិសុខសណ្តាប់ធ្នាប់សង្គមធ្វើឱ្យប្រជាពលរដ្ឋខ្មែរមានការព្រួយបារម្ភពីសុវត្ថិភាពនិងមុខរបបរចិញ្ចឹមជីវិតប្រចាំថ្ងៃ។

[5] នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត សុខ ផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ លើកឡើងក្នុងកម្មវិធីសំណេះ សំណាល ជាមួយនាយនគរបាលជាន់ខ្ពស់ និងនាយកនគរបាល នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨។

ជនអន្ធពាលចិនអាចយកទឹកដីកម្ពុជាធ្វើជាកន្លែងប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ដូចជាការចាប់ជំរិតតាមរូបភាពផ្សេងៗ ការបាញ់បោះអាណាធិបតេយ្យ បុកសម្លាប់ដោយគ្រោះថ្នាក់ចរាចរជាដើម។

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ បានឱ្យដឹងថា បច្ចុប្បន្នជនជាតិចិនកំពុងស្នាក់នៅកម្ពុជាមានចំនួនប្រមាណ២១ម៉ឺននាក់ក្នុងនោះជាង៧ម៉ឺននាក់នៅខេត្តព្រះសីហនុ[6]។ ក្រៅពីធ្វើការវិនិយោគ សាងសង់ អន្តោប្រវេសន៍ជនជាតិចិនមួយចំនួនតែងតែបង្កបទល្មើសផ្សេងៗជាបន្តបន្ទាប់។ ប្រសិនបើអាជ្ញាធរមិនអាចទប់ស្កាត់ និងគ្រប់គ្រងស្ថានភាពមិនបានទេ សេចក្តីបារម្ភរបស់ប្រជាពលរដ្ឋខ្មែរនឹងអាចក្លាយជាជម្ងឺស្អប់ខ្ពើមជាតិសាសន៍ឬអាចបន្ថយការគាំទ្រលើគោលនយោបាយសហប្រតិបត្តិការរវាងរដ្ឋាភិបាលខ្មែរនិងចិនផងដែរ។ ដូច្នេះហើយរដ្ឋាភិបាលចាំបាច់ត្រូវតែពង្រឹងគុណភាពក្នុងការអនុវត្តច្បាប់ការងារ និងច្បាប់អន្តោប្រវេសន៍នៃកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

ឥទ្ធិពលនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការលើការអនុវត្តន៍គោលនយោបាយជាយុទ្ធសាស្ត្រដ៏យូរអង្វែង នៃវិថីសូត្រ ឬផ្លូវមួយខ្សែក្រវ៉ាត់មួយរវាងប្រទេសកម្ពុជានិងប្រទេសចិន ធ្វើឱ្យជនជាតិចិនមានមោទនភាពលើសពីពេលណាទាំងអស់។ មោទនភាពនេះអាចទៅហួសព្រំដែននៃសិទ្ធិអំណាចរបស់ខ្លួន។ ភាគច្រើននៃអន្តោប្រវេសន៍ចិនចំណូលថ្មីនេះ ហាក់មានឥរិយាបថរើសអើង ក្រអឺតក្រទម មើលងាយ វាយឬកចំពោះពលរដ្ឋខ្មែរ។ ការទិញដូរទំនិញសេវាសព្វសារពើប្រព្រឹត្តទៅតែរវាងចិននិងចិនដូចគ្នា។ នេះប្រហែលអាចមកពីលក្ខខណ្ឌនៃភាសា ប៉ុន្តែវាគ្រាន់តែជាលេសមួយប៉ុណ្ណោះ។ ការមិនទិញ ឬប្រើប្រាស់សេវាដែលពលរដ្ឋខ្មែរដែលមិនជាប់ខ្សែស្រឡាយចិន គឺជាឥរិយាបថមួយដែលទាក់ទងនឹងការរើសអើង។ ជាទូទៅជនជាតិចិនចេះជួយសាសន៍ចិនដូចគ្នាណាស់។ ចិនចូលចិត្តរាប់អានមនុស្សដែលមានឈាមជ័រវង្សត្រកូលកូនចៅចិនដូចគ្នាល្អជាងការរាប់អានជាមួយសាសន៍ដទៃ។ គេចេះយឹតយោងគ្នា និងចេះជួយគ្នាជាទម្លាប់ប្រពៃណីរហូតមក។ កតញ្ញូកតវេទិតាធម៌ និងការចេះតស៊ូកំចាត់សត្រូវដើម្បីសងសឹកជូនអ្នកមានឧបការគុណត្រូវបានគេចាត់ទុកថាជាគុណធម៌មួយពិសេសសម្រាប់ជនជាតិចិន។ កូនប្រុសត្រូវស្នងនិងការពារវង្សត្រកូលដូនតា ទើបព្រលឹងដូនតាតាមជួយថែរក្សាផ្តល់នូវសេចក្តីសុខចម្រើន។ ថ្វីត្បិតបដិវត្តវប្បធម៌ចិនមានការផ្លាស់ប្តូរទម្រង់ជំនឿខ្លះក៏ដោយ ក៏ផ្នត់គំនិតនិងស្មារតីជនជាតិចិនសម័យបុរាណនិងទំនើប នៅតែរក្សាបាននូវអត្តសញ្ញាណចិនបែបនេះដដែល។

## ៤. ច្បាប់គតិយុត្តិសម្រាប់ដោះស្រាយបញ្ហាជនជាតិចិនចំណូលថ្មី

ច្បាប់ការងារ និងច្បាប់អន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈគ្រប់គ្រាន់ក្នុងការអនុវត្តលើជនជាតិចិនបាន គឺពុំទាន់ចាំបាច់បង្កើតច្បាប់ការងារ និងច្បាប់អន្តោប្រវេសន៍ដោយឡែកសម្រាប់តែករណីពិសេសលើជនជាតិចិននោះឡើយ។

យោងតាមច្បាប់ការងារកម្ពុជា យើងអាចយកមកអនុវត្តសម្រាប់អន្តោប្រវេសន៍ចិនបាន ពោលគឺ គ្មានជនបរទេសណាម្នាក់ អាចប្រកបមុខរបរណាមួយដោយគ្មានប័ណ្ណការងារ និងសៀវភៅការងារដែលចេញឱ្យដោយក្រសួងទទួលបន្ទុកវិស័យការងារឡើយ។ ជនបរទេសទាំងនោះត្រូវបំពេញបណ្តាលក្ខខណ្ឌផ្សេងៗទៀតដូចតទៅ៖

[6] https://www.postkhmer.com/ ព័ត៌មានជាតិ/លោក-ហ៊ុន-សែន-ពន្យល់ពីវត្តមានចិននៅកម្ពុជា

ក. ត្រូវមានជាមុននូវប័ណ្ណការងារត្រឹមត្រូវ ដើម្បីប្រកបមុខរបររបស់ខ្លួននៅព្រះរាជាណាចក្រកម្ពុជា

ខ. ត្រូវបានចូលមកព្រះរាជាណាចក្រកម្ពុជាដោយត្រឹមត្រូវតាមច្បាប់

គ. ត្រូវមានលិខិតឆ្លងដែនត្រឹមត្រូវ

ឃ. ត្រូវមានប័ណ្ណស្នាក់នៅត្រឹមត្រូវ

ង. ត្រូវមានកាយសម្បទាសមស្របនឹងមុខរបរនោះហើយគ្មានកើតជំងឺឆ្លងណាមួយទេ (លក្ខខណ្ឌនេះត្រូវបានកំណត់ដោយប្រកាសក្រសួងសុខាភិបាល ដោយមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យការងារ)។

ប័ណ្ណការងារត្រូវមានតម្លៃត្រឹមរយៈពេលមួយឆ្នាំ ហើយអាចនឹងពន្យារពេលក្នុងករណីដែលសុពលភាពនៃការពន្យារនេះ មិនលើសរយៈពេលកំណត់នៃប័ណ្ណស្នាក់នៅរបស់ជនបរទេសនោះ។ ការទទួលជនបរទេសឱ្យធ្វើការត្រូវអនុវត្តតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួងមហាផ្ទៃមានសិទ្ធិត្រួតពិនិត្យប័ណ្ណការងាររបស់ជនបរទេសនៅតាមរោងចក្រ សហគ្រាស ក្រុមហ៊ុន គ្រឹះស្ថាននានា ដោយសហការជាមួយក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន។

ចំណែកច្បាប់ស្តីពីអន្តោប្រវេសន៍១៩៩៤ កម្ពុជាក៏មានលក្ខណៈសមស្របសម្រាប់យកមកអនុវត្តចំពោះអន្តោប្រវេសន៍ចិនបានដែរ គឺច្បាប់នេះគ្រប់គ្រងជនបរទេសគ្រប់រូប ដែលមកស្នាក់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ ជនបរទេសដែលគ្មានសញ្ជាតិជាខ្មែរ ទោះមានជំនឿ សាសនា ឬមានដើមកំណើតអ្វីក៏ដោយ ឱ្យតែបង្ហាញនូវសម្បទានផលប្រយោជន៍ដល់សេដ្ឋកិច្ច ឬសង្គមកិច្ច ឬវិទ្យាសាស្ត្របច្ចេកទេស ឬវប្បធម៌សម្រាប់ព្រះរាជាណាចក្រកម្ពុជា ឱ្យតែបំពេញឱ្យបាននូវលក្ខខណ្ឌផ្នែកសន្តិសុខដែលព្រះរាជាណាចក្រកម្ពុជាតម្រូវឱ្យមាន។ ជនបរទេសទាំងអស់ពេលចូលក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង្ហាញខ្លួននៅប៉ុស្តិ៍ត្រួតពិនិត្យអន្តោប្រវេសន៍ទាំងពេលមកដល់ និងពេលចេញដំណើរទៅវិញ ដែលគ្រប់ច្រកឬចំណុចចេញចូលទាំងនោះ ត្រូវកំណត់និងគ្រប់គ្រងដោយក្រសួងមហាផ្ទៃ។ ការឈប់ទទួលស្គាល់ជនបរទេសណាម្នាក់ជាជនអន្តោប្រវេសន៍ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ជាគោលការណ៍ ជនបរទេសអាចធ្វើចរាចរបានដោយសេរីនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ក៏ប៉ុន្តែក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចដាក់បញ្ញត្តិហាមឃាត់ចរាចរ និងហាមឃាត់ជនអន្តោប្រវេសន៍ ឬមិនមែនអន្តោប្រវេសន៍ទាំងអស់មិនឱ្យចូល ឬស្នាក់អាស្រ័យនៅក្នុងតំបន់ ឬចាកចេញឆ្ងាយពីតំបន់ ឬកន្លែងណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា។ ម្ចាស់ឬអ្នកកាន់កាប់លំនៅដ្ឋានគ្រប់ប្រភេទត្រូវជូនដំណឹងក្នុងរយៈពេល២៤ម៉ោងដល់ស្ថាប័ននគរបាលមានសមត្ថកិច្ចពីវត្តមាននៃជនអន្តោប្រវេសន៍ឬមិនមែនអន្តោប្រវេសន៍ដែលបានមកស្នាក់នៅ។ ប័ណ្ណស្នាក់នៅចេញឱ្យលើកដំបូងមានសុពលភាពសម្រាប់រយៈពេលពីរឆ្នាំ។ ប័ណ្ណស្នាក់នៅនេះអាចសុំបន្តការប្រើប្រាស់បានរាល់ពីរឆ្នាំម្តង។ ស្នងការដ្ឋាននគរបាលខេត្ត ក្រុង ត្រូវទទួលខុសត្រូវត្រួតពិនិត្យជនបរទេសទាំងអស់ដែលបានតាំងទីលំនៅ ឬទើបនឹងមកតាំងទីលំនៅក្នុងដែនដីក្រោមសមត្ថកិច្ចរបស់ខ្លួន។ ជនណាដែលគ្មានការអនុញ្ញាត ហើយចូលមកព្រះរាជាណា



វេលាម៉ោង២រសៀលថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៦ អគ្គនាយកដ្ឋានអន្តោប្រវេសន៍បានឃាត់ខ្លួនជនជាតិចិន១២នាក់ដែលគ្មានលិខិតឆ្លងដែនក្នុងចំណោមជនបរទេស ៥០នាក់ នៅក្នុងការដ្ឋានសំណង់ចិនមួយកន្លែងស្ថិតនៅតាមផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ផ្សារ ដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។
ដោយ ស តារា http://nokorwatnews.com/ អគ្គនាយកដ្ឋានអន្តោប្រ-13/

ចក្រកម្ពុជាដោយលបលាក់បន្លំ ឬដោយល្បិចផ្សេងទៀតដែលផ្ទុយនឹងបញ្ញត្តិនៃច្បាប់នេះត្រូវផ្តន្ទាទោសដាក់គុកពីបីខែដល់ប្រាំមួយខែមុននឹងត្រូវបណ្តេញចេញ។ ត្រូវផ្តន្ទាទោសដូចគ្នានឹងជនល្មើសចំពោះជនណាដែលផ្តល់ជំនួយ ឬជួយលាក់បាំងក្នុងការបញ្ចូលជនបរទេសដែលគ្មានការអនុញ្ញាតមកក្នុងព្រះរាជាណាចក្រកម្ពុជា។

មន្ត្រី ឬភ្នាក់ងាររាជការមានសមត្ថកិច្ចរូបណាដែលជាអ្នកសមគំនិត ឬជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើសខាងលើ ត្រូវផ្តន្ទាទោសដាក់គុកពីប្រាំមួយខែដល់មួយឆ្នាំ។ មន្ត្រី ឬភ្នាក់ងាររាជការមានសមត្ថកិច្ចរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជា ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល។ មធ្យោបាយសម្ភារៈប្រើសម្រាប់ប្រព្រឹត្តបទល្មើសត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋដោយតុលាការ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជារាល់ជនអន្តោប្រវេសន៍ណាដែលរំលោភលើបញ្ញត្តិច្បាប់អន្តោប្រវេសន៍។ លើសពីនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានសិទ្ធិបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា រាល់ជនណាដែលមានអាកប្បកិរិយា និងសកម្មភាពគ្រោះថ្នាក់ដល់សន្តិសុខជាតិនៃព្រះរាជាណាចក្រកម្ពុជា ឬមានភ័ស្តុតាងដាក់លាក់ថាជននោះជាអ្នកប្រឆាំងនឹងសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា ឬជនណាដែលចូលមកធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានប័ណ្ណការងារ ឬជនណាដែលចូលក្នុងព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់។ សេចក្តីសម្រេចបណ្តេញចេញត្រូវអនុវត្តភ្លាម ចាប់ពីថ្ងៃចុះហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ការបណ្តេញចេញត្រូវអនុវត្តក្នុងរយៈពេល៧ថ្ងៃយ៉ាងយូរ ក្រោយពីសេចក្តីសម្រេចចេញជាផ្លូវការពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែមានសាលក្រមផ្អាកការអនុវត្តពីតុលាការ។ សាមីខ្លួនមានសិទ្ធិប្តឹងទៅតុលាការក្នុងរយៈពេល២ខែ។ល។

## ៩. ជនជាតិចិនចំណូលថ្មីបានបង្កើនការទារដល់អាជ្ញាធរមានសមត្ថកិច្ចកម្ពុជា

ក្នុងចំណោមបទល្មើស ដែលបង្កឡើងដោយជនបរទេស ជនជាតិចិនបង្កបទល្មើសច្រើនជាងគេបំផុតនៅកម្ពុជា។ ឧទហរណ៍ នៅក្នុងរយៈពេល៦ខែឆ្នាំ២០១៨ ជនបរទេសដែលបានប្រព្រឹត្តបទល្មើសមានចំនួន៨៨ករណី ឃាត់ខ្លួន៣៧៨នាក់ មាន២៥សញ្ជាតិ។ ក្នុងចំណោមបទល្មើសទាំងនោះ ភាគច្រើនជាបទល្មើសប្រើប្រាស់ជួញដូរគ្រឿងញៀនមាន ចំនួន១៧ករណី ស្មើនឹង១៩,៣១% នៃចំនួនសរុប៨៨ករណី ក្នុងនោះជនជាតិចិនបានប្រព្រឹត្តបទល្មើសច្រើនជាងគេគឺចំនួន២៥៧នាក់, នីហ្សេរីយ៉ា៣៧នាក់, វៀតណាម១៤នាក់, ថៃ១២នាក់, កូរ៉េខាងត្បូង០៨នាក់ ហើយភូមិសាស្ត្រដែលកើតមានច្រើនជាងគេនៅរាជធានីភ្នំពេញ។

ថ្ងៃទី២ ខែសីហា ឆ្នាំ២០១៧ កម្លាំងនគរបាលអន្តោប្រវេសន៍ សហការជាមួយកម្លាំងនគរបាលខេត្តបន្ទាយ-មានជ័យ បានឃាត់ខ្លួនជនជាតិចិនជិត២០០នាក់ដែលប្រព្រឹត្តបទល្មើសឆបោក គំរាមកំហែង ជំរិតទារប្រាក់តាមប្រព័ន្ធបច្ចេកវិទ្យាទូគមនាគមន៍ (VOIP) ព្រមទាំងបានរឹបអូសវត្ថុតាងប្រព្រឹត្តបទល្មើសមួយចំនួន និងបានរកឃើញបញ្ជីឈ្មោះជនរងគ្រោះនៅប្រទេសចិនដែលសម្រាប់គំរាមជំរិតទារប្រាក់។

ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ កម្លាំងនគរបាលអគ្គនាយកដ្ឋានអន្តោប្រវេសន៍បញ្ជូនជនជាតិចិនចំនួន ១៦០នាក់ចេញពីប្រទេសកម្ពុជាតាមយន្តហោះតាមព្រលានយន្តហោះអន្តរជាតិខេត្តសៀមរាប។ ជនជាតិចិនទាំង

នោះ ជាប់ពាក់ព័ន្ធនឹងករណីចាប់ជំរិតទារប្រាក់តាមប្រព័ន្ធ Internet ដែលត្រូវបានប៉ូលិសអន្តោប្រវេសន៍កម្ពុជា ចាប់ខ្លួន នៅគោលដៅចំនួន២ ស្ថិតនៅភូមិក្បាលស្ពាន សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ[7]។




ក្រុមជនជាតិ ចិន ដែលត្រូវបានចាប់ខ្លួនពីបទចាប់ជំរិតតាមអ៊ិនធើណេត ត្រូវបញ្ជូនទៅប្រទេសចិន វិញ កាលពីថ្ងៃទី ១៥ ខែតុលា ២០១៨ ។ ដោយ ហេង ជីវ័ន

យប់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោង១៩.៤០នាទី ជនជាតិចិនឈ្មោះ ស៊ាង ជាងស៊ាន (Zhang Jiangshan) ភេទប្រុស អាយុ២៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ E92895358 បានលោតពីអាគារ៨ជាន់ពីកាស៊ីណូផ្កាយ៥ស្ថិតក្នុងភូមិសាមគ្គីមានជ័យក្រុងប៉ោយប៉ែតដោយមិនដឹងពីមូលហេតុ និងស្លាប់ភ្លាមនៅនឹងកន្លែង។[8]

ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អាជ្ញាធរកម្ពុជាបានចុះបង្ក្រាបទីតាំងចាប់ជំរិតតាមប្រព័ន្ធអ៊ីនធឺណិតចំនួន៤កន្លែងស្ថិតក្នុងឃុំត្រពាំងក្រញូងស្រុកតាំកក់ និងឃុំតាំងដូងស្រុកបាទីនៃខេត្តតាកែវ។ ក្រោយប្រតិបត្តិការចុះបង្ក្រាបនេះ អាជ្ញាធរបានឃាត់ខ្លួនជនបរទេស២៣៥នាក់ ក្នុងនោះជនជាតិចិនមានច្រើនជាងគេរហូតដល់២៣៣នាក់[9]។

ចុងខែវិច្ឆិកា បុរស-ស្ត្រី ជនជាតិចិន២៣៥នាក់ត្រូវបានកម្លាំងសមត្ថកិច្ចនគរបាលក្រសួងមហាផ្ទៃសហការជាមួយកម្លាំងសមត្ថកិច្ចនគរបាលខេត្តតាកែវចាប់ឃាត់ខ្លួនពាក់ព័ន្ធករណីចាប់ជំរិតតាមប្រព័ន្ធអ៊ីនធឺណិត[10]។

---

[7] http://news.pnn.com.kh/news/169

[8] https://www.dap-news.com/2018/11/09 /បុរសជនជាតិចិនម្នាក់-លោត/

[9] https://www.vodhotnews.com/2018/11/28/88666/gov-is-stepping-up-measures-against-the-chinese-in-sihanoukville/

[10] https://www.postkhmer.com/ព័ត៌មានជាតិ/បុរសជនជាតិចិន-ដែលបង្កហិង្សាកាប់មនុស្សឱ្យរបួស-ត្រូវបញ្ជូនទៅតុលាការ

រសៀល ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៨ បុរសម្នាក់ឈ្មោះ ជិន ជុន (Jin Chun) អាយុ៣៧ឆ្នាំ ជនជាតិចិន ត្រូវបានចាប់ខ្លួនបន្ទាប់ពីបានប្រើកាំបិតប៉័ងតោកាប់ទៅលើមន្ត្រីនគរបាលអន្តោគមន៍ម្នាក់ឈ្មោះ ម៉ៅ សំណាង និងស្ត្រីលក់អំពៅសាងឈ្មោះ មាស សាលី អាយុ៧០ឆ្នាំបណ្តាលឱ្យរងរបួសនៅផ្លូវ៤៣២ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ និងបានយកកាំបិតកាប់ក្បាលខ្លួនឯងម្តងហើយម្តងទៀតបណ្តាលឱ្យហូរឈាមដោកខ្លួន។ សមត្ថកិច្ចបានចាប់បុរសជនជាតិចិននោះដាក់ខ្នោះយកទៅព្យាបាលរបួសនៅមន្ទីរពេទ្យរុស្ស៊ី។ យោងតាមការធ្វើកោសល្យវិច័យទៅលើទឹកនោម ជនសង្ស័យមានផ្ទុកសារធាតុញៀន។ ជនសង្ស័យត្រូវបានបញ្ជូនខ្លួនទៅកាន់តុលាការរាជធានីភ្នំពេញដោយចោទប្រកាន់ពីបទហិង្សាដោយចេតនា។

អធ្រាត្រ ថ្ងៃទី២ ខែធ្នូ នៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ឈ្មោះ Li Ruming ភេទប្រុស អាយុ២៤ ឆ្នាំជនជាតិចិនត្រូវសមត្ថកិច្ចចាប់ខ្លួនពីបទចាក់សម្លាប់ឈ្មោះ Wa Rong ភេទប្រុសជនជាតិចិន ដែលអ្នកទាំង២ ជាបុគ្គលិកភោជនីយដ្ឋាន Hu Ming Tan ដូចគ្នា ។ សមត្ថកិច្ចថា ករណីនេះជារឿងគំនុំ។[11]

ខាងលើនេះ គ្រាន់តែជាឧទាហរណ៍ ដើម្បីបញ្ជាក់កស្តុតាងខ្លះប៉ុណ្ណោះ។ មានករណីជាច្រើនដែលកើតមានដែលត្រូវធ្វើការស្រាវជ្រាវលំអិតដែលតម្រូវឱ្យកងកម្លាំងអាជ្ញាធរមានសមត្ថកិច្ចធ្វើការសកម្មខ្លាំងក្លាបំផុត។ អគ្គស្នងការដ្ឋាននគរបាលជាតិបានយកចិត្តទុកដាក់ការពារ និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋខ្លួន និងការការពារសន្តិសុខ សុវត្ថិភាព ជូនវិនិយោគិន ភ្ញៀវទេសចរណ៍បរទេស មន្ត្រីការទូត ទីតាំងស្ថានទូត និងនិវេសនដ្ឋានឯកអគ្គរាជទូត រដ្ឋទូតដែលមានវត្តមាននៅកម្ពុជា។[12]

## ១០. ការព្រួយបារម្ភចំពោះឥរិយាបថជនជាតិចិននៅកម្ពុជាបច្ចុប្បន្ន

សកម្មភាពនិងអំពើដែលស្តែងឡើងដោយជនជាតិចិនមានស្ទើរគ្រប់រូបភាព។ វិបាកនៃអំពើទាំងនេះបានបន្ថយសេចក្តីរីករាយដល់ទេសចរ និងប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងមូលដ្ឋានដែលមានជនជាតិចិនចំណូលថ្មីរស់នៅច្រើន ជាពិសេសតំបន់មាត់សមុទ្រ ក្រុងព្រះសីហនុ។ ពលរដ្ឋខ្មែរភាគច្រើនដែលបានទៅលេងក្រុងព្រះសីហនុបានបង្ហាញការភ័យខ្លាចចំពោះឥរិយាបថជនជាតិចិន។ អ្នកខ្លះបានសរសេរនៅលើបណ្តាញសង្គមហ្វេសប៊ុកថា ជនជាតិចិននៅក្រុងព្រះសីហនុបានសម្លក់សំឡឹងខ្មែរក្នុងន័យមើលស្រាល ចិនបើកបរឡានមានលក្ខណៈព្រហើនក្នុងល្បឿនលឿនគ្មានប្រណី ចិនផឹកស៊ីឡូឡាបង្កជម្លោះ ឈ្លោះប្រកែកវាយកាប់ចាក់គ្នា ដោយសាររឿងគំនុំសងសឹកដណ្តើមស្រី ឬដោយឥទ្ធិពលគ្រឿងញៀណ។ល។ ចិនចោលសម្រាម និងកាកសំណល់ធ្វើឱ្យបាត់សណ្តាប់ធ្នាប់របៀបរៀបរយ និងបាត់សោភ័ណភាពនៅទីតាំងតំបន់កំសាន្តសម្រាប់ទេសចរ។ វត្តមានអន្តោប្រវេសន៍ចិននៅកម្ពុជាពិតជាផ្តល់វិបាកខ្លាំងដល់មុខរបរចិញ្ចឹមជីវិតរបស់ពលរដ្ឋខ្មែរ ជាពិសេសអ្នកដែលរស់នៅនៅក្រុងព្រះសីហនុ។

ការិយាល័យអ្នកនាំពាក្យរាជរដ្ឋាភិបាល បានចេញសេចក្តីថ្លែងការណ៍ ចុះផ្សាយកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្នុងន័យថា ពេលថ្មីៗនេះ អ្នកប្រើប្រាស់បណ្តាញសង្គមបានចែករំលែកព័ត៌មានមួយចំនួនស្តីពីភាពមិនប្រក្រតីនៅក្រុងព្រះសីហនុដែលពាក់ព័ន្ធនឹងជនជាតិចិន។ ការិយាល័យអ្នកនាំពាក្យរាជរដ្ឋាភិបាល សូមបញ្ជាក់ថា

---

[11] https://kohsantepheapdaily.com.kh/article/743874.html

[12] នាយឧត្តមសេនីយ៍ ថោង លីម អគ្គស្នងការរងនគរបាលជាតិនិងជាប្រធានក្រុមព័ត៌មានទាន់ហេតុការណ៍(HOTLINE) ថ្លែងនៅក្នុងកិច្ចប្រជុំត្រួតពិនិត្យបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទី២ ឆ្នាំ២០១៨ កាលពីព្រឹកថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨។

រាជរដ្ឋាភិបាលបាននឹងកំពុងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការពង្រឹងសន្តិសុខសុវត្ថិភាព ក៏ដូចជាសណ្តាប់ធ្នាប់សង្គមសម្រាប់បម្រើផលប្រយោជន៍សាធារណៈនៅតំបន់នោះ។ កន្លងទៅរដ្ឋាភិបាលបានឃាត់ខ្លួនអ្នកបរទេសជាបន្តបន្ទាប់ និងបញ្ជូនជនទាំងនោះទៅប្រទេសដើមវិញ ក្រោយរកឃើញថាពួកគេមិនគោរពច្បាប់កម្ពុជា។

ដើម្បីទប់ស្កាត់កុំឱ្យមានភាពមិនប្រក្រតីនៅក្រុងព្រះសីហនុបាន រដ្ឋាភិបាលបញ្ជូនសមត្ថកិច្ចជាច្រើនទៅការពារ២៤ម៉ោងនៅតំបន់សំខាន់ៗ និងធ្វើការអប់រំផ្នែកច្បាប់ដល់ម្ចាស់អាជីវកម្ម និងអ្នកគ្រប់គ្រងជនបរទេសទាំងនោះជាដើម។ ស្នងការនគរបាលជាតិបានបន្ថែមកម្លាំងសមត្ថកិច្ចឱ្យបានច្រើនសម្រាប់ខេត្តនេះ ព្រោះរាល់ថ្ងៃកម្លាំងសមត្ថកិច្ចមានចំនួនតិច។ ពេលមានរឿងកើតឡើងកម្លាំងសមត្ថកិច្ចពិបាករកមនុស្សធ្វើការងារ។ មួយទៀត សុំឱ្យធ្វើការផ្សព្វផ្សាយពីច្បាប់កម្ពុជា ពីច្បាប់ព្រហ្មទណ្ឌ ហើយនិងគោលការណ៍ក្នុងការការពារសន្តិសុខសណ្តាប់ធ្នាប់ក្នុងខេត្តនេះទៅដល់ខាងក្រុមហ៊ុន ឬទៅតាមទីកន្លែងដែលមានជនជាតិចិនដែលគាត់ធ្វើការងារឬគាត់រស់នៅ។ គេមានការព្រួយបារម្ភដោយសារកំណើនជនជាតិចិនចូលមករស់នៅប្រកបមុខរបរគ្រប់ប្រភេទកាន់តែច្រើន ហើយបទល្មើសដែលបង្កដោយជនជាតិចិនមានកាន់តែច្រើនជាលំដាប់ឥតថយចុះ។

ក្នុងឆ្នាំ២០១៧ ជនបរទេសចូលមកស្នាក់នៅក្នុងខេត្តព្រះសីហនុ មានចំនួន៦៣៨៥នាក់ ក្នុងនោះជនជាតិចិនមានច្រើនជាងគេគឺ៤៤៩៨នាក់ ឥណ្ឌូណេស៊ី៩០៩នាក់ ហ្វីលីពីន១២៧នាក់ ម៉ាឡេស៊ី១២២នាក់ និងជនជាតិផ្សេងៗទៀត[13]។ អគ្គនាយកអន្តោប្រវេសន៍ ក៏បានសម្តែងការព្រួយបារម្ភចំពោះសកម្មភាពឧក្រិដ្ឋជនជាតិចិនដែលបន្លំខ្លួនជាអ្នករកស៊ីនៅកម្ពុជា។ កន្លងមកសមត្ថកិច្ចបានឃាត់ខ្លួនជនជាតិចិនជាច្រើននាក់ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសចាប់ជំរិតតាមប្រព័ន្ធអ៊ីនធើណិត។

យើងមានការព្រួយបារម្ភដោយសារតែក្នុងនោះមានជនជាតិចិនខ្លះ រស់នៅដោយអត់ស្របច្បាប់ ហើយបានប្រព្រឹត្តបទល្មើសទៀតឧទាហរណ៍ដូចឃើញហើយថា យើងបានចាប់បញ្ជូនកន្លងមកជាច្រើន[14]។ ទោះជាយ៉ាងណាឧក្រិដ្ឋជនជាតិចិនដែលបន្លំខ្លួននៅកម្ពុជានេះនៅមិនទាន់អស់នៅឡើយទេ ហើយមន្ត្រីអន្តោប្រវេសន៍ទាំងអស់ ត្រូវយកចិត្តទុកដាក់សិក្សាស្វែងយល់ឱ្យបានច្បាស់លាស់ចំពោះករណីនេះដើម្បីឈានដល់ការបង្ក្រាបឱ្យបានទាន់ពេលវេលា ព្រោះវាជាបញ្ហាគួរឱ្យមានការព្រួយបារម្ភដល់សន្តិសុខជាតិនិងអន្តរជាតិ។ ទន្ទឹមនឹងការព្រួយបារម្ភអំពីឧក្រិដ្ឋជនជាតិចិន ក៏គួរគាំទ្រនិងលើកសរសើរវិនិយោគិនចិននៅកម្ពុជាដែលរកស៊ីត្រឹមត្រូវស្របតាមច្បាប់ផងដែរ។ រហូតដល់ពេលនេះមានជនជាតិចិនប្រមាណ៧ម៉ឺននាក់ ក្នុងនោះមិនគិតពីអ្នកទេសចរ អ្នកការទូត និង NGO ជាជនជាតិនោះឡើយ[15]។

ចំណែកនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានពន្យល់ប្រាប់ទៅប្រជាពលរដ្ឋខ្លះដែលមានទុក្ខកង្វល់ពាក់ព័ន្ធកំណើនជនជាតិចិនថា ការកើនឡើងនៃជនជាតិចិននេះមួយផ្នែកគឺដោយសារតែប្រទេសកម្ពុជាខ្វះកម្លាំងពលកម្មជំនាញដើម្បីបម្រើដល់ការសាងសង់ ហើយជនជាតិចិនដែលមកបម្រើក្នុងវិស័យសំណង់ទាំងនោះនឹងត្រឡប់ទៅប្រទេសខ្លួនវិញបន្ទាប់ពីការសាងសង់បានបញ្ចប់។

---

[13] របាយការណ៍អភិបាលខេត្តព្រះសីហនុ ចុះកាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

[14] នាយឧត្តមសេនីយ៍ សុខ ផល ថ្លែងក្នុងពិធីបំពាក់ឋានន្តរស័ក្តិជូននាយនគរបាល នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៅក្រសួងមហាផ្ទៃ នាព្រឹកថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧។

[15] http://m.freshnewsasia.com/index.php/en/localnews/59967-2017-07-14-09-49-09.html

«...សំណង់ច្រើនត្រូវការកម្មករនិងជំនាញច្រើន យើងផ្តល់ឱ្យគេមិនគ្រប់គ្រាន់។ ដូច្នេះត្រូវបើកឱកាសឱ្យគេយកកម្មករមកសាងសង់សំណង់ ដូចជាស្ពាននិងអ្វីផ្សេងៗទៀត។ នៅពេលដែលគេកសាងហើយ គេមិននៅស្រុកខ្មែរទេ គេទៅស្រុកគេវិញហើយកុំឆ្ងល់ពេក ហើយយើងក៏គ្មានច្បាប់អនុញ្ញាតឱ្យគេនៅដែរ...»[16]។

យោងតាមរបាយការណ៍របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃបានបង្ហាញថា ក្នុងរយៈពេល៤ឆ្នាំ (២០១៤ ដល់២០១៨) ជនសង្ស័យជាជនជាតិចិនភាគច្រើនបានប្រព្រឹត្តបទល្មើសគឺ៖

១. បទល្មើសគំរាមជំរិតឆបោកតាមប្រព័ន្ធទូរគមនាគមន៍សរុបមានចំនួន១៥៦៧នាក់ ក្នុងនោះស្រីចំនួន៣០៩នាក់។

២. បទល្មើសសេដ្ឋកិច្ច (នៅប្រទេសចិន) សមត្ថកិច្ចស្នើសុំសហការចាប់ខ្លួនសរុបចំនួន៨២នាក់ក្នុងនោះស្រីចំនួន១០នាក់។

សម្រាប់ឆ្នាំ២០១៨ គិតត្រឹមថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៨ ជនជាតិចិនដែលបានប្រព្រឹត្តបទល្មើសគំរាមជំរិតឆបោកតាមប្រព័ន្ធទូរគមនាគមន៍ មានចំនួនសរុប ៣៧៣នាក់ ក្នុងនោះស្រីចំនួន៦៦នាក់។ បទល្មើសសេដ្ឋកិច្ច (នៅប្រទេសចិន) សមត្ថកិច្ចស្នើសុំសហការចាប់ខ្លួនសរុបចំនួន៣៤នាក់ ក្នុងនោះស្រីចំនួន៧នាក់[17]។



ជំនួបពិភាក្សាលើកិច្ចសហប្រតិបត្តិការកម្ពុជាចិន នៅព្រឹកថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨ នាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ និង លោក LIAO JINRONG អគ្គនាយកកិច្ចសហប្រតិបត្តិការអន្តរជាតិនៃក្រសួងសន្តិសុខសាធារណៈចិន។

ភាគីចិន ដឹកនាំដោយ លោក LIAO JINRONG អគ្គនាយកកិច្ចសហប្រតិបត្តិការអន្តរជាតិនៃក្រសួងសន្តិសុខសាធារណៈចិនបានមកដល់ប្រទេសកម្ពុជា ដើម្បីធ្វើកិច្ចសហប្រតិបត្តិការដោះស្រាយបញ្ហា សន្តិសុខសាធារណៈ ដោយបានជួបពិភាក្សាប្តូរយោបល់ជាមួយសមភាគីកម្ពុជា ដឹកនាំដោយនាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ។ ភាគីចិនបានសម្តែងនូវការអរគុណដល់កងកម្លាំងនគរបាលកម្ពុជាដែលបានសហការដើម្បីរក្សាសន្តិភាពសណ្តាប់ធ្នាប់សុវត្ថិភាពបង្កើនការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក ដើម្បីបង្រ្កាបបទល្មើស និងជម្រុញឱ្យអ្នកវិនិយោគចិនដែលកំពុងតែមករកស៊ីនៅប្រទេសកម្ពុជា ដាច់ខាតត្រូវតែគោរពច្បាប់និងទំនៀមទម្លាប់ប្រពៃណីរបស់កម្ពុជា ហើយប្រសិនមានជនជាតិចិនណាធ្វើខុសច្បាប់ ត្រូវបង្រ្កាបដោយមិនឱ្យមានការយោគយល់នោះឡើយ[18]។

សរុបជារួម យើងអាចនិយាយបានថា ខ្មែរនិងចិនធ្លាប់មានទំនាក់ទំនងផ្នែកវប្បធម៌ជាមួយគ្នាជាយូរណាស់មកហើយ។ ចិនឆៅដែលបានភៀសខ្លួនពីទឹកដីចិនមករស់នៅលើទឹកដីខ្មែរតាំងពីយូរមកហើយនោះ បានសមាហរ-

---

[16] នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីសំណេះសំណាលជាមួយសហគមន៍ខ្មែររស់នៅទ្វីបអឺរ៉ុប នាទីក្រុងហ្សឺណែវ ប្រទេសស្វ៊ីស នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ ។

[17] https://www.dap-news.com/2018/12/02/

[18] http://www.khmertalking.com/kt-social/55564

ណាកម្មសម្របខ្លួនក្នុងសង្គមខ្មែររួមរស់នៅយ៉ាងសុខស្រួលដោយគ្មានការរើសអើងស្អប់ខ្ពើមពីខ្មែរម្ចាស់ស្រុកឡើយ។ ចិនសញ្ជាតិខ្មែរមានឥរិយាបថល្អ អាកប្បកិរិយាសមរម្យ ប្រព្រឹត្តអំពើសុចរិតទាំងកាយវាចាចិត្ត គោរពតាមគន្លងសុជីវធម៌ សីលធម៌ និង គុណធម៌ខ្មែរបានដោយគ្មានបញ្ហា។ ចិនសញ្ជាតិខ្មែរ(កូនចៅចិន)បានរួមចំណែកយ៉ាងសកម្មក្នុងសមាគមចិន សាលារៀនភាសាចិន ព្រះវិហារចិន ភោជនីយដ្ឋានម្ហូបអាហារចិន វិទ្យុផ្សាយសំឡេងជាភាសាចិន និងក្រុមហ៊ុនចិនជាច្រើនទៀត។ គេបង្កើតក្រុមហ៊ុនវិនិយោគលើវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង សហគ្រាសសំណង់ស្ពានថ្នល់ជាដើម។ កូនចៅចិនភាគច្រើនមានជីវភាពល្អ ជាអ្នកសម្បូរទ្រព្យធន ខ្លះមានមុខដំណែងខ្ពង់ខ្ពស់ក្នុងជួររដ្ឋាភិបាលផង។ ខ្មែរចូលរួមប្រារព្ធពិធីបុណ្យចូលឆ្នាំចិន បុណ្យសែនលោកខែ បុណ្យសែនក្បាលទឹក បុណ្យឆេងម៉េង ។ល។ ចិននិយមកូនប្រុស ព្រោះកូនប្រុសអាចស្នងបន្តនាមត្រកូល ការពារវង្សត្រកូលដូនតា ដោយជំនឿថាព្រលឹងដូនតានឹងតាមជួយថែរក្សាផ្តល់នូវសេចក្តីសុខចម្រើនដល់ការរស់នៅរបស់កូនចៅ។ ខ្មែរទទួលស្គាល់ថា ចិនជាមនុស្សស្អាត។

ពាក្យស្លោកថា «កុំឈ្លោះនឹងស្រី កុំក្តីនឹងចិន» និង «ចិនដេញខ្មែរ ខ្មែរដេញខ្មោច» នៅមានសុពលភាពនៅឡើយ។ ពាក្យស្លោកនេះវានឹងអស់តម្លៃនៅពេលដែលសង្គមខ្មែររៀបចំឱ្យមានកម្រិតសមធម៌សមរម្យមួយ។ សង្គមខ្មែរគោរពលទ្ធិមាតាធិបតេយ្យ គឺលើកស្ទួយនិងឱ្យតម្លៃស្ត្រីខ្ពស់បំផុត ការឈ្លោះនឹងស្ត្រីនាំឱ្យអាប់ឱនកិត្តិយស ហើយក្តីនឹងចិនមិនងាយឈ្នះចិនឡើយព្រោះចិនពូកែរកលុយនិងពូកែខាងប្រើលុយក្នុងការសូកប៉ាន់។

ឥរិយាបថជនជាតិចិនសម័យថ្មី ឬ អន្តោប្រវេសន៍ចិនសតវត្សទី២១នៅកម្ពុជា មានលក្ខណៈខុសប្លែកពីសតវត្សរ៍មុន។ ជនជាតិចិនសតវត្សទី២១នៅកម្ពុជា អាចជាចំណែកមួយនៃការអនុវត្តគោលនយោបាយសេដ្ឋកិច្ចចិន ផ្លូវមួយខ្សែក្រវ៉ាត់មួយ។ មហិច្ឆតារដ្ឋាភិបាលចិនគឺចង់ពង្រីកឥទ្ធិពលនយោបាយសេដ្ឋកិច្ចដើម្បីដណ្តើមកិត្យានុភាពនិងពង្រីកតួនាទីជាមហាអំណាចពិភពលោក។  ការកើនឡើងយ៉ាងគំហុកនៃជនជាតិចិនដើម្បីការងារនៅកម្ពុជា បានបង្កឱ្យមានបទល្មើសគ្រឿងញៀន សងសឹក វាយកាប់ចាក់ សម្លាប់គ្នា និងបង្កបទល្មើសលួច ឆក់ប្លន់ ចាប់ជំរិត។ល។ ការណ៍នេះបានគម្រាមដល់សន្តិសុខសណ្តាប់ធ្នាប់សង្គម ធ្វើឱ្យប្រជាពលរដ្ឋខ្លះព្រួយបារម្ភពីសុវត្ថិ-ភាព និងមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ។ នាយករដ្ឋមន្ត្រីនៃរាជាណាចក្រកម្ពុជា លើកឡើងថា ការកើនឡើងនៃជនជាតិចិននេះមួយផ្នែកគឺដោយសារតែប្រទេសកម្ពុជាខ្វះកម្លាំងពលកម្មជំនាញដើម្បីបម្រើដល់ការសាងសង់ ហើយជនជាតិចិនដែលមកបម្រើក្នុងវិស័យសំណង់ទាំងនោះនឹងត្រឡប់ទៅប្រទេសខ្លួនវិញបន្ទាប់ពីការសាងសង់បានបញ្ចប់។

ឥរិយាបថខុសឆ្គងនៃជនជាតិចិនចំណូលថ្មី បានបង្កើនការងារច្រើនបន្ថែមទៀតដល់អាជ្ញាធរមានសមត្ថកិច្ចនៅកម្ពុជា។ ក្នុងចំណោមបទល្មើស ដែលបង្កឡើងដោយជនបរទេស ជនជាតិចិនបង្កបទល្មើសច្រើនជាងគេបំផុតនៅកម្ពុជា។ ជនអន្ធពាលចិនអាចប្រើទឹកដីកម្ពុជាកន្លែងប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម ចាប់ជំរិត លាងលុយកខ្វក់ តាមរូបភាពផ្សេងៗ ដូចជាការបាញ់ ឬបុកសម្លាប់ ការបង្កើតបនល្បែងស៊ីសង បនពេស្យា។ល។ ប្រសិនបើអាជ្ញាធរមិនអាចទប់ស្កាត់ និងគ្រប់គ្រងស្ថានភាពមិនបាន សេចក្តីបារម្ភរបស់ប្រជាពលរដ្ឋខ្មែរនឹងអាចជាជម្ងឺស្អប់ខ្ពើមជាតិសាសន៍ និងបំផ្លាញដល់គោលនយោបាយរដ្ឋាភិបាលខ្មែរនិងចិនផងដែរ។ ទន្ទឹមនឹងការព្រួយបារម្ភអំពីឧក្រិដ្ឋកម្មជនជាតិចិន ក៏គួរគាំទ្រនិងលើកសរសើរ វិនិយោគិនចិននៅកម្ពុជាដែលរកស៊ីត្រឹមត្រូវស្របតាមច្បាប់ផងដែរ។ អាជ្ញាធរមានសមត្ថកិច្ចកម្ពុជា សហការជាមួយភាគីចិន បានបង្ហាញការខិតខំប្រឹងប្រែងពង្រឹងការអនុវត្តច្បាប់ការងារ និង ច្បាប់អន្តោប្រវេសន៍មានលក្ខណៈកាន់តែសកម្មនិងលំបាកជាងមុន។

## សេចក្ដីសន្និដ្ឋាន

យោងតាមការរៀបរាប់និងបង្ហាញភ័ស្តុតាងខ្លះខាងលើ យើងអាចសន្និដ្ឋានបានថា នយោបាយសេដ្ឋកិច្ចនៃមហាអំណាចចិនជះឥទ្ធិពលក្នុងការកែប្រែផ្លាស់ប្តូរឥរិយាបថអន្តោប្រវេសន៍ចិននៅសតវត្សនេះឱ្យខុសពីសម័យកាលមុន។ ជនជាតិចិនដែលភៀសខ្លួនពីសម័យមុននាំយកតែវប្បធម៌និងចេះរៀនរស់នៅដោយសម្របខ្លួនទៅនឹងសង្គមខ្មែរបានដោយគ្មានបង្កការលំបាកដល់ម្ចាស់ស្រុកឡើយ។ ចំណែកជនជាតិចិនចំណូលថ្មីសតវត្សរ៍ទី២១ បាននាំនូវបញ្ហាជាច្រើនតាមរយៈការប្រព្រឹត្តគ្រឿងញៀន លាងលុយកខ្វក់ និងការចាប់ជំរិត។ល។ នេះជារបត់ថ្មីមួយដែលអង្រួនស្មារតីខ្មែរគ្រប់ស្រទាប់វណ្ណៈឱ្យមានការប្រុងប្រយ័ត្នជាទីបំផុត។ របត់ថ្មីនេះបង្កើតឱ្យមានឱកាសការងារនិងការបាត់បង់ការងារផងដែរ។ កងកម្លាំងមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន គ្រប់ស្ថាប័នជាប់ពាក់ព័ន្ធបានបង្កើនបរិមាណនិងពង្រឹងគុណភាពរបស់ខ្លួនកាន់តែខ្លាំងក្លាថែមទៀតដើម្បីអនុវត្តច្បាប់ដែលមានស្រាប់ឱ្យមានប្រសិទ្ធ-ភាពខ្ពស់។ ចំណែកប្រជាពលរដ្ឋដែលជាអាជីវករ កសិករ មន្ត្រីបុគ្គលិកគ្រប់អង្គភាព ស្ថាប័ន បានប្រឹងប្រែងថែមទៀតដើម្បីប្រកួតប្រជែងរត់ឱ្យទាន់ជំហានសេដ្ឋកិច្ចទីផ្សាសេរីប្រកបដោយសេចក្តីសុចរិត និងអំណត់អត់ធ្មត់បំផុតប្រឈមទល់នឹងជនជាតិចិន។

ក្នុងដំណើរអភិវឌ្ឍន៍កម្ពុជាប្រកបដោយនិរន្តរភាព យើងគួររួមគ្នារៀបចំផែនការជាយុទ្ធសាស្ត្រសមស្របដើម្បីដោះស្រាយឥរិយាបថអវិជ្ជមានដែលបង្កឡើងដោយអន្តោប្រវេសន៍ចិន ក៏ដូចអន្តោប្រវេសន៍បរទេសនានានៅកម្ពុជា កុំឱ្យមានគុណវិបត្តិដល់វប្បធម៌និងសង្គមជាតិ ដើម្បីចៀសវាងការស្អប់ខ្ពើម និងការរើសអើងរវាងជាតិសាសន៍។ កិច្ចការនេះ ជាការទទួលខុសត្រូវរួម មិនមែនជាអម្រែករបស់បុគ្គលណាមួយទេ។ ការណ៍នេះតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការខ្ពស់ និងចេះលើកទឹកចិត្តគ្នាទៅវិញទៅមក។ គេមិនគួរយកអំណាចនៃការចេះដឹង ឬឋានៈតួនាទីណាមួយដើម្បីកេងចំណេញពីការទទួលយកតែខាងត្រូវ ហើយមើលងាយទម្លាក់កំហុសដល់អ្នកទន់ទាប និងខ្សោយជាងខ្លួននោះទេ។

ទោះបីមានកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់សកម្មភាពនិងអំពើដែលបង្កដោយជនជាតិចិនជាបន្តបន្ទាប់ក៏ដោយ ក៏វាមិនទាន់គ្រប់គ្រាន់នៅឡើយ សំខាន់ត្រូវយល់ដឹងពីមូលហេតុពិតប្រាកដ ថាតើពលរដ្ឋចិនដែលធ្លាប់រស់នៅក្នុងប្រទេសដែលមានអារ្យធម៌របស់ខ្លួនក្នុងឋានៈជាប្រទេសមហាអំណាចពិភពលោក ហេតុអ្វីបានជាមានជនពាលប្រព្រឹត្តល្មើសច្បាប់នៅក្រៅប្រទេស ជាពិសេសនៅកម្ពុជា មានចំនួនយ៉ាងច្រើនសម្បើមបែបនេះ? ដូច្នេះការស្រាវជ្រាវស៊ីជម្រៅមួយលើបញ្ហាជនបរទេសជនជាតិចិននៅកម្ពុជាបច្ចុប្បន្ន គួរធ្វើបន្តទៀតដើម្បីស្វែងរកឱ្យឃើញច្បាស់ពីអ្វីដែលនៅពីក្រោយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់មហាអំណាចចិនមកលើប្រទេសកម្ពុជា។

## ឯកសារពិគ្រោះ


១. ងួន ញ៉ិល ព្រលឹងមាតាធិបតេយ្យក្នុងសង្គមខ្មែរ ភ្នំពេញ ១៩៩២

២. ជីវតាក្វាន់ ប្រពៃណីនៃអ្នកស្រុកចេនឡា បកប្រែដោយលីធាមតេង ភ្នំពេញ ១៩៧៣

៣. ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ភ្នំពេញ ១៩៧៣

៤. មជ្ឈមណ្ឌលសិក្សាជាន់ខ្ពស់ ក្រុមជនជាតិភាគតិច ភ្នំពេញ ២០០៩

៥. លោកស្រី កី ធៀន ឡាយ កម្រងសុជីវធម៌ ភ្នំពេញ ១៩៦៩

៦. វិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា វិធីបុណ្យទំនៀមទម្លាប់ប្រពៃណីជនជាតិចិន ភ្នំពេញ ២០១១
៧. សរ សារុន សង្គមវិជ្ជាខ្មែរ ភ្នំពេញ ១៩៧៣
៨. សុខ សុត្ថាល ទស្សនវិជ្ជាខុងជឺ រំលោយមហាកំពែងចិន ភាគ២ ភ្នំពេញ ១៩៧៣?

**គេហទំព័រ**

១. https://www.postkhmer.com
២. http://news.pnn.com.kh
៣. https://www.dap-news.com
៤. https://www.vodhotnews.com
៥. https://kohsantepheapdaily.com.kh
៦. http://m.freshnewsasia.com
៧. http://km.rfi.fr
៨. https://www.rfa.org/khmer
៩. https://thmeythmey.com